# ការភ្ជាប់មែក

ការភ្ជាប់មែក គឺជាការនាំយកដើមរុក្ខជាតិពីដើមមួយដែលមួយដើមៗសុទ្ធតែមានរឹសនិងត្រូវនាំយកមកផ្សារភ្ជាប់ជាសាច់តែមួយលើដើមមួយទៀត ក្រោយពេលធ្វើការភ្ជាប់មែកពូជល្អ ជាមួយដើមទម្ររហូតដល់ជាប់គ្នាហើយទើបកាត់មែកភ្ជាប់ចេញពីដើមមេ។



<u>ជំហានទី១៖</u> ត្រៀមដើមភ្ជាប់ដែលនឹងនាំទៅភ្ជាប់ ដោយបិតបង្ហាប់ស្រកីដូងចូលក្នុងថង់ប្លាស្ទិកដើម្បីឱ្យមានទម្ងន់ស្រាល និងប្រមូលនូវសំណើមទុកបានយូរ។



<u>ជំហានទី២៖</u> យកដើមត្រូវភ្ជាប់ដែលត្រៀមទុកមកវាស់ភ្ជាប់ជាមួយមែកពូជល្អ ដើម្បីមើលថាតើគួរនឹងចៀរដើមតនិងមែកពូជបានយ៉ាងណា។



<u>ជំហានទី៣៖</u> យកដើមតមកកាត់ត្រួយចេញហើយប្រើកាំបិតចៀរបញ្ឈិតជាមាត់ឆ្លាម ដូចគ្នាដែរចិតមែកពូជដើម្បីភ្ជាប់រួចភ្ជាប់ចូលរកគ្នាឱ្យជិត។



<u>ជំហានទី៤៖</u> ប្រើប្លាស្ទិករុំដើមតទុកជាមួយមែកឱ្យណែន រយៈពេលប្រមាណ ២ខែទើបភ្ជាប់គ្នាជាសាច់មួយបានយ៉ាងជិត។

## ចុចដើម្បីភ្ជាប់ប៉ុស្តិ៍តេឡេក្រាមរបស់គម្រោង

## រៀនពីបច្ចេកទេសកសិកម្ម

| @LASEDIII_ANIMAL_HUSBANDRY | @LASEDIII_PLANTING | @LASEDIII_FISH_FARMING | @MARTKETPLACE_LASEDIII |
|---|---|---|---|
| ក្រុមចិញ្ចឹមសត្វ | ក្រុមដាំដំណាំ | ក្រុមវារីវប្បកម្ម | ព័ត៌មានទីផ្សារ |

THE WORLD BANK
IBRD • IDA | WORLD BANK GROUP


### អាសយដ្ឋានទំនាក់ទំនង

+855 12 837 656
lasediii.info@maff.gov.kh
មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ


ហ្វេសបុក    គេហទំព័រ

# គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ដំណាក់កាលទី៣

## សាលារៀនស្រែកសិករ

### បច្ចេកទេស សាក តភ្នែក តមែក និងភ្ជាប់មែក ដំណាំ



# ការសាក

ការសាកជាការបំបែកពូជរុក្ខជាតិ ដោយប្រើប្រភេទវិធីមួយដែលធ្វើអោយមែករុក្ខជាតិកើតរឹសក្នុងខណៈដែលនៅជាប់និងដើមមេ។ ពេលមែកចេញរឹសល្អហើយក៏កាត់ទៅផ្សាំមុនដាំឬយកទៅដាំតែម្តងក៏បាន ។



ជំហានទី១៖ ការសាក គឺជាការអង្កន់បរិមាណក្រោមថ្នាំង ហើយបកសម្បកចេញព្រមទាំងយកសរសៃនាំចេញផង។



ជំហានទី២៖ ជាការនាំយកដីមកហ៊ុមបរិវេណ ដែលចៀរសម្បកចេញ ដោយរុំផ្នែកលើចុះមកក្រោមមុនហ៊ុមដីនេះអាចប្រើ Hormone សំរាប់ជំនួយការចេញរឹសត្រង់កន្លែងកាត់ផ្នែកលើ។



ជំហានទី៣៖ យកស្រកីដូងដែលបានត្រាំទឹកមុន ២-៣ថ្ងៃហ៊ុមជុំវិញដីហើយចងឱ្យណែន ។



ជំហានទី៤៖ ក្រោយពេលហ៊ុមស្រកីដូងរួចទើបហ៊ុមបាស្ទិកជាន់ក្រៅមួយជាន់ទៀតដើម្បីជួយប្រមូលនូវភាពសើម។

# ការតភ្នែក

ការភ្ជាប់ភ្នែក គឺជាវិធីបំបែកពូជរុក្ខជាតិមួយផ្នែកទៀតដែលនាំយកផែនភ្នែកពីមែកពូជល្អ (ផល) ទៅភ្ជាប់ជាមួយដើមទម្រ ដើម្បីអោយបានពូជតាមតម្រូវការហើយអាចរីកធំធាត់ជារុក្ខជាតិដើមជាមួយគ្នាបាន ឧ៖ ដូចក្នុងរូបភាពខាងក្រោម។



ជំហានទី១៖ ឆូតដើមជារូបអក្សរតេ T រួចហើយប្រើកាំបិតមួយផ្នែកផ្សេងដើម្បីបើកសំបកចេញ។



ជំហានទី២៖ ជ្រើសរើសភ្នែកដែលកំពុងរីកចម្រើនពីមែកពូជល្អ ចៀរយកភ្នែកអោយជាប់សាច់ឈើមកផង តែយកសាច់ឈើចេញមុននឹងដាក់សៀតចូលក្នុងដើមទម្រដែលបម្រុងទុកជាស្រេច។



ជំហានទី៣៖ យកផ្នែករបស់ភ្នែកដែលបានឆ្កឹះទុក ដែលយកសាច់ឈើចេញហើយនោះទៅស៊កចូលនៅក្នុងកន្លែងដែលបើកសម្បកទុកនៅដើមទម្រ។



ជំហានទី៤៖ ពេលស៊កចូលរៀបរយហើយរុំដោយប្លាស្ទិកដើម្បីការពារទឹកចូល ទុកចោលរយៈពេល១៥-២០ថ្ងៃ ភ្នែកនឹងរីកចម្រើនភ្ជាប់ជាមួយនឹងដើម ទើបបើកប្លាស្ទិកដែលយើងរុំនោះចេញ។

# ការតមែក

ការតមែក ជាការបំបែកពូជដោយនាំយកមែកពូជដែលមានភ្នែកច្រើនជាងមួយ ទៅធ្វើការតភ្ជាប់មែកលើដើមទម្រ ដើម្បីឱ្យបានពូជល្អតាមតម្រូវការដែលមែកពូជល្អ និងដើមទម្រនេះនឹងរីកចម្រើនជារុក្ខជាតិដើមតែមួយ។

## ក. ការតមែកបែបសៀតពីចំហៀង



ជំហានទី១៖ ចៀរដើមទម្រផ្នែកចំហៀងបញ្ឆិតចុះក្រោមទៅឱ្យជ្រៅប្រមាណ ១/៣នៃដើម ហើយនាំយកមែកដែលពូជល្អ មកចិតជាបញ្ឆិតរួចសៀតចូលទៅត្រង់ផ្នែកចំហៀងនៃដើមទម្រ។



ជំហានទី២៖ ពេលសៀតមែកពូជល្អចូលជាមួយដើមទម្រហើយ ត្រូវរុំដោយប្លាស្ទិកឱ្យណែន។

## ខ. ការតមែកបែបសៀតចំសាច់ឈើ



ជំហានទី១៖ ពុះដើមបរិវេណពាក់កណ្តាលអោយជ្រៅល្មម។



ជំហានទី២៖ យកមែកពូជល្អមកចិតផ្នែកចុងសងខាងរាងសំប៉ែត រួចសៀតចូលទាំងពីរផ្នែកភ្ជាប់ជាមួយសម្បករបស់ដើម ក្រោយពីនោះប្រើក្រមួនលាបបិតមាត់ប្រហោងឱ្យជិតការពារទឹកចូល។